ការស្តារឡើងវិញនៃភាពពេញលេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ

ការប្រកាសដល់ពិភពលោកនៃខួបលើកទីពីរឆ្នាំ

គណៈប្រធានទីមួយ
និងក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

យើង សូម ប្រកាស ជា ឧឡារិក ថា ព្រះ ស្រឡាញ់បុត្រាបុត្រីរបស់ទ្រង់គ្រប់ជាតិសាសន៍នៅក្នុង ពិភពលោក នេះ ។ ព្រះ ជា ព្រះបិតា បាន ប្រទានដល់ យើង នូវ កំណើត ដ៏ទេវភាព ជា ជីវិត ដែល ឥត ប្រៀបធ្ងឹម និង ពលិកម្ម ធួន ដ៏ និរន្តរ៍ នៃ ព្រះរាជបុត្រា សំណព្វរបស់ ទ្រង់ គឺ ព្រះយេស៊ូវគ្រីស្ទ ។ ដោយ ព្រះចេស្តា នៃ ព្រះបិតា នោះព្រះយេស៊ូវបានរស់ឡើងវិញម្តងទៀត ហើយបានទទួលជ័យជម្នះលើ សេចក្តីស្លាប់ ។ ទ្រង់គឺជាព្រះអង្គសង្គ្រោះរបស់យើង ជាគំរូរបស់យើង និងជាព្រះ ប្រោសលោះរបស់យើង ។

ពីរឆ្នាំកន្លងទៅ នៅព្រឹកនិទាឃរដូវដ៏ស្រស់ស្អាតមួយក្នុងឆ្នាំ ១៨២០ យុវជន យ៉ូសែប ស្ម៊ីធ កំពុងស្វែងរកដោយចង់ដឹងថាគួរចូលរួមព្រះវិហារមួយណា គាត់ បានចេញទៅក្នុងព្រៃនៅជិតផ្ទះគាត់ នៅប៉ែកខាងជើងរដ្ឋនូវយ៉ោកសហរដ្ឋអាមេរិក ដើម្បីអធិស្ឋាន ។ គាត់បានសួរសំណួរទាក់ទងទៅនឹងសេចក្តីសង្គ្រោះនៃព្រលឹង គាត់ ហើយទុកចិត្តថាព្រះនឹងដឹកនាំគាត់ ។

យើងសូមប្រកាសដោយរាបសាថា នៅក្នុងចម្លើយចំពោះការអធិស្ឋានរបស់គាត់ ព្រះជាព្រះបិតា និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ បានលេចមកជួបយ៉ូសែប ហើយបានផ្តើម « តាំងរបស់ទាំងអស់ឡើងវិញ » (កិច្ចការ ៣:២១) ដូចបាន ទាយទុកក្នុងព្រះគម្ពីរប៊ីប ។ នៅក្នុងការនិមិត្តនេះ គាត់បានរៀនថា បន្ទាប់ពីការ ស្លាប់របស់ពួកសាវកជំនាន់ដើម នោះព្រះវិហាររបស់ព្រះគ្រីស្ទក្នុងសញ្ញាថ្មីត្រូវបាន បាត់បង់ពីផែនដី ។ យ៉ូសែបនឹងធ្វើជាឧបករណ៍ក្នុងការនាំវាត្រឡប់មកវិញ ។

យើងសូមអះអាងថា នៅក្រោមការដឹកនាំរបស់ព្រះបិតា និងព្រះរាជបុត្រា នោះ សារទូតសួគ៌បានយាងមកបង្រៀនដល់យ៉ូសែប ហើយបានស្ថាបនាសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទឡើងវិញ ។ យ៉ូហានបាទីស្ទដែលបានរស់ឡើងវិញបានស្តារ សិទ្ធិអំណាចដើម្បីធ្វើពិធីបុណ្យជ្រមុជទឹកដោយការពន្លិចសម្រាប់ការផ្តាច់បាប ។ ពួកសាវកបីនាក់ក្នុងចំណោមពួកសាវកដប់ពីរនាក់កាលពីដើម—ពេត្រុស យ៉ាកុប និងយ៉ូហាន—បានស្តារភាពជាសាវក និងកូនសោនៃសិទ្ធិអំណាចបព្វជិតភាព ឡើងវិញ ។ អ្នកផ្សេងទៀតបានយាងមកផងដែរ រួមមានទាំង អេលីយ៉ា ដែល បានស្តារ សិទ្ធិអំណាច ដើម្បី ចងភ្ជាប់ ក្រុមគ្រួសារ ជាមួយគ្នា ជា រៀងរហូត នៅ ក្នុង ទំនាក់ទំនងដ៏អស់កល្បជានិច្ចដែលហួសពីសេចក្តីស្លាប់ ។

យើងសូមធ្វើជាសាក្សីបន្ថែមថា យ៉ូសែប ស្ម៊ីធ ត្រូវបានប្រគល់អំណោយទាន និង អំណាច នៃ ព្រះ ដើម្បី បកប្រែ កំណត់ត្រា ពី បុរាណ គឺ ព្រះ គម្ពីរ មរមន— សក្ខីបទមួយទៀតអំពី ព្រះយេស៊ូវគ្រីស្ទ ។ ទំព័រនៃអត្ថបទពិសិដ្ឋនេះ រួមមាននូវ ដំណើររឿងនៃការបម្រើដោយផ្ទាល់របស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងចំណោមអរិស្តេ នៅអឌ្ឍគោលខាងលិចភ្លាមៗបន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ។ វា បង្រៀនអំពីគោលបំណងនៃជីវិត ហើយពន្យល់អំពីគោលលទ្ធិនៃព្រះគ្រីស្ទ ដែល សំខាន់ ចំពោះគោលបំណងនោះ ។ ជាដៃគូគម្ពីរទៅនឹងគម្ពីរប៊ីប ព្រះគម្ពីរ មរមន ថ្លែងទីបន្ទាល់ថា មនុស្សគ្រប់រូបគឺជាបុត្រាបុត្រីនៃព្រះបិតាសួគ៌ជាទីស្រឡាញ់ ថា ទ្រង់មានផែនការដ៏ទេវភាពសម្រាប់ជីវិតរបស់យើង ហើយថាព្រះរាជបុត្រា របស់ ទ្រង់ ព្រះយេស៊ូវគ្រីស្ទ មានបន្ទូលនៅសព្វថ្ងៃនេះ ក៏ដូចជាពីជំនាន់មុនដែរ ។

យើង សូម ប្រកាសថា សាសនាចក្រ នៃ ព្រះយេស៊ូវគ្រីស្ទ នៃ ពួក បរិសុទ្ធ ថ្ងៃ ចុង ក្រោយ ដែលបានរៀបចំឡើងនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ គឺជាព្រះវិហារ របស់ ព្រះគ្រីស្ទ ក្នុង សញ្ញាថ្មី ដែលបាន ស្តារឡើងវិញ ។ សាសនាចក្រ នេះ គឺ ជា យុថ្កា នៅ ក្នុង ជីវិត ដ៏ ឥតខ្ចោះ នៃ ថ្មជ្រុង យ៉ាងឯក គឺ ព្រះយេស៊ូវគ្រីស្ទ និង នៅក្នុង ដង្វាយធួនដ៏ និរន្តរ៍ និងការរស់ឡើងវិញដ៏ពិតរបស់ទ្រង់ ។ ព្រះយេស៊ូវគ្រីស្ទបាន ហៅពួកសាវកជាថ្មីម្តងទៀត ហើយបានប្រគល់សិទ្ធិអំណាចបព្វជិតភាពដល់ពួកគេ ។ ទ្រង់អញ្ជើញយើងទាំងអស់គ្នាឲ្យមករកទ្រង់ និងសាសនាចក្ររបស់ទ្រង់ ដើម្បី ទទួលព្រះវិញ្ញាណបរិសុទ្ធ ពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះ និងដើម្បីទទួលបានអំណរ ដ៏ខ្ជាប់ខ្ជួន ។

ពីរឆ្នាំបានកន្លងហួសទៅហើយ ចាប់តាំងពីការស្តារឡើងវិញត្រូវបានចាប់ផ្តើម ដោយព្រះ ជា ព្រះបិតា និង ព្រះរាជបុត្រា សំណព្វ របស់ទ្រង់ គឺ ព្រះយេស៊ូវគ្រីស្ទ ។ មានមនុស្សរាប់លាននាក់នៅទូទាំងពិភពលោក បានឱបក្រសោបយកចំណេះដឹង មួយនៃព្រឹត្តការណ៍ដែលបានព្យាករទុកទាំងនេះ ។

យើង រីករាយ នឹង ប្រកាស ថា ការស្តារឡើងវិញ ដែលបាន សន្យា នោះ បន្ត ឆ្ពោះទៅមុខ តាមរយៈ វិវរណៈ ជា បន្តបន្ទាប់ ។ ផែនដី នឹង ពុំ នៅ ដដែល ឡើយ នៅពេលព្រះនឹង « បំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ » (អេភេសូរ ១:១០) ។

ដោយគារវភាព និងការដឹងគុណ ពួកយើងជាសាវករបស់ទ្រង់ សូមអញ្ជើញមនុស្ស ទាំងអស់ ឲ្យ បាន ដឹង— ដូចជា យើងបានដឹង— ថា ស្ថានសួគ៌ បាន បើក ។ យើង អះអាង ថា ព្រះ កំពុង បង្ហាញ ព្រះឆន្ទៈ របស់ទ្រង់ ចំពោះ បុត្រាបុត្រី ជា ទីស្រឡាញ់ របស់ទ្រង់ ។ យើង ថ្លែង ទីបន្ទាល់ ថា អស់ អ្នក ដែល សិក្សា សារលិខិត អំពី ការ ស្តារឡើងវិញនេះប្រកបដោយការអធិស្ឋាន ហើយធ្វើសកម្មភាពដោយជំនឿ នឹង ត្រូវប្រទានពរឲ្យទទួលបានសាក្សីផ្ទាល់ខ្លួនអំពីទេវភាព និងគោលបំណងរបស់វា នៅក្នុងការរៀបចំពិភពលោកសម្រាប់ការយាងមកជាលើកទីពីរ របស់ព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទរបស់យើង ដូចដែលបានសន្យា ។

ការប្រកាសនេះត្រូវបានអានដោយប្រធាន រ័សុល អិម ណិលសុន
ជាផ្នែកមួយនៃសារលិខិតរបស់លោកនៅក្នុងសន្និសីទទូទៅប្រចាំឆ្នាំលើកទី ១៩០
នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០២០ នៅក្នុងទីក្រុងសលត៍ លេក រដ្ឋយូថាហ៍ ។

Unofficial poster layout of the text published on churchofjesuschrist.org. Not an official publication of The Church of Jesus Christ of Latter-day Saints. Generated by Urim, urim.samuelbaird.com